LONG BEACH
CITY COLLEGE

# ការិយាល័យអធិការបតីនៃ
# ហាវិទ្យាល័យសហគមន៍នៃរដ្ឋកាលីហ្វ័រញ៉ា (CCCCO)
# ការណែនាំផ្លូវច្បាប់
# ព័ត៌មានអំពីការអនុវត្តច្បាប់អន្តោប្រវេសន៍




Nohel Corral អនុប្រធានប្រតិបត្តិ ផ្នែកសេវាកម្មសម្រាប់និស្សិត

Lee Douglas អនុប្រធាន ផ្នែកកិច្ចការសិក្សា

Loy Nashua អនុប្រធាន ផ្នែកធនធានមនុស្ស

# បេសកកម្ម និងគុណតម្លៃ

LONG BEACH
CITY COLLEGE

## បេសកកម្ម

Long Beach City College (LBCC, មហាវិទ្យាល័យនៃទីក្រុងឡុងប៊ិក) ប្តេជ្ញាផ្តល់ភាពអង់អាចដល់និស្សិតរបស់យើងក្នុងការមានភាពសកម្ម ក្លាយជាអ្នកចូលរួមប្រកបដោយក្រមសីលធម៌ក្នុងការសិក្សា ក៏ដូចជាក្នុងរចនាសម្ព័ន្ធប្រជាធិបតេយ្យដែលផ្តល់សំឡេង និងទីភ្នាក់ងារឱ្យពួកគេ ដើម្បីរៀបចំសង្គម និងមជ្ឈដ្ឋានរបស់ពួកគេ។ ក្នុងមជ្ឈដ្ឋានដែលចេះយកចិត្តទុកដាក់ ចេះជួយគ្នា និងរាប់បញ្ចូលគ្រប់គ្នា LBCC លើកកម្ពស់ការសិក្សាដោយស្មើភាព និងសមិទ្ធផលអប់រំតាមរយៈការផ្តល់កម្មវិធីសញ្ញាបត្រ កម្មវិធីឧត្តមសិក្សាគុណភាពខ្ពស់ដែលមានលក្ខណៈច្នៃប្រឌិតថ្មី សេវាជំនួយគ្រប់សព្វ និងការរៀបចំកម្លាំងពលកម្មឈានមុខគេសម្រាប់សហគមន៍ចម្រុះរបស់យើង។

## គុណតម្លៃ

Long Beach City College បង្កើតសមត្ថភាព កសាងសហគមន៍ និងចាប់ផ្តើមការច្នៃប្រឌិតថ្មី ដោយគាំទ្រការប្រឆាំងនឹងការរើសអើងជាតិសាសន៍ និងរាប់បញ្ចូលគ្រប់គ្នា ដើម្បីជានាថាកម្មវិធី និងសេវាកម្មអាចបំផុសគំនិត និងជួយឱ្យអ្នកសិក្សាត្រៀមខ្លួនរីកចម្រើនក្នុងនាមជាពលរដ្ឋក្នុងលិទ្ធិប្រជាធិបតេយ្យចម្រុះ និងសម្រេចគោលដៅផ្នែកបញ្ញា ហិរញ្ញវត្ថុ និងផ្ទាល់ខ្លួនបាន។ យើងបណ្តុះសហគមន៍ដែលឱបក្រសោបបុគ្គលនានាយ៉ាងពេញលេញដែលមកពីគ្រប់សាវតារ វប្បធម៌ ជាតិសាសន៍ អត្តសញ្ញាណ បទពិសោធជីវិត ទស្សនៈ ជំនឿ សមត្ថភាព និងគុណតម្លៃ។

# ការណែនាំផ្លូវច្បាប់

## 11/15/24

## រដ្ឋកាលីហ្វ័រញ៉ា និងមហាវិទ្យាល័យសហគមន៍របស់ខ្លួននៅតែមានដែនសមត្ថកិច្ចលើទីជម្រក

## តំណ៖

## [ការណែនាំផ្លូវច្បាប់]

ព័ត៌មានថ្មីៗបន្ថែមនឹងផ្តល់ជូន នៅពេលមាន

LONG BEACH CITY COLLEGE



# លិខិតណែនាំយោងតាម Assembly Bill 21 (សេចក្តីព្រាងច្បាប់សភាលេខ 21)

ហាមឃាត់រដ្ឋ និងទីភ្នាក់ងារក្នុងតំបន់មិនឱ្យប្រើជនធាន ដើម្បីបន្តកិច្ចខិតខំអនុវត្តន៍ច្បាប់អន្តោប្រវេសន៍សហព័ន្ធមួយចំនួន។

- **កំណត់ឱ្យមណ្ឌលសិក្សាធិការនៃមហាវិទ្យាល័យសហគមន៍**ទប់ស្កាត់និស្សិតបុគ្គលិក និងមហាវិទ្យាល័យកុំឱ្យចូលរួមកិច្ចខិតខំអនុវត្តន៍ច្បាប់អន្តោប្រវេសន៍សហព័ន្ធ លុះត្រាតែតម្រូវដោយច្បាប់រដ្ឋ ឬសហព័ន្ធ។

## កាតព្វកិច្ចខាងក្រោមត្រូវបានដាក់ក្រោមសេចក្តីព្រាងច្បាប់ AB21៖

# 1. ការការពារព័ត៌មានផ្ទាល់ខ្លួន

A. មណ្ឌលសិក្សាធិការនៃមហាវិទ្យាល័យមិនត្រូវបញ្ចេញព័ត៌មានផ្ទាល់ខ្លួនអំពីនិស្សិត មហាវិទ្យាល័យ និងបុគ្គលិកជាដាច់ខាត។

1) ករណីលើកលែងទាំងប្រាំ៖

a) នៅពេលមានការយល់ព្រមត្រឹមត្រូវ

b) នៅពេលច្បាប់រដ្ឋ និងសហព័ន្ធស្តីពីឯកជនភាពអនុញ្ញាតឱ្យបញ្ចេញ

c) នៅពេលចាំបាច់ក្នុងការអនុវត្តកម្មវិធី ដែលត្រូវទទួលបានព័ត៌មាន

d) នៅពេលបញ្ចូលក្នុងបញ្ជីរាយឈ្មោះ ដែលមិនរួមបញ្ចូលអាសយដ្ឋានស្នាក់នៅ ឬកាលវិភាគវគ្គសិក្សារបស់បុគ្គល ហើយបុគ្គលនោះមិនបានជ្រើសរើសដកឈ្មោះចេញពីបញ្ជីរាយនាមនោះ

e) ឬនៅពេលឆ្លើយតបនឹងដីកាតុលាការ សេចក្តីបង្គាប់ពីតុលាការ ឬដីកាកោះ។

## 2. សេចក្តីជូនដំណឹងអំពីសកម្មភាពអនុវត្តន៍ច្បាប់អន្តោប្រវេសន៍

A. មណ្ឌលសិក្សាធិការនៃមហាវិទ្យាល័យត្រូវតែណែនាំនិស្សិតមហាវិទ្យាល័យ និងបុគ្គលិកទាំងអស់ឱ្យជូនដំណឹងទៅការិយាល័យប្រធានមហាវិទ្យាល័យភ្លាមៗ ប្រសិនបើរំពឹងថាមានមន្ត្រីអន្តោប្រវេសន៍ចូល នឹងចូល ឬបានចូលបរិវេណមហាវិទ្យាល័យ ដើម្បីអនុវត្តបទបញ្ញាអន្តោប្រវេសន៍សហព័ន្ធ។

- ការិយាល័យនាយក/ប្រធាន៖ lzale@lbcc.edu

# 3. ការជូនដំណឹងទៅបុគ្គលទំនាក់ទំនងពេលមានអាសន្ន

A. ប្រសិនបើមានហេតុផលសង្ស័យថានិស្សិត មហាវិទ្យាល័យ ឬ បុគ្គលិកណាម្នាក់ត្រូវបាននាំខ្លួនទៅឃុំដោយសារវិធានការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ មណ្ឌលសិក្សាធិការនៃមហាវិទ្យាល័យត្រូវជូនដំណឹងភ្លាមៗទៅបុគ្គលទំនាក់ទំនងពេលមានអាសន្នរបស់សាមីខ្លួន។ អ្នកដែលត្រូវរាយការណ៍ទៅ៖

- និស្សិត - Deborah Miller-Calvert ព្រឹទ្ធបុរសផ្នែកកិច្ចការនិស្សិត dmiller-calvert@lbcc.edu
- បុគ្គលិក - Rick von Kolen, AVPHR; rvonkolen@lbcc.edu

# 4. ការអនុលោមតាមដីកាតុលាការ និងដីកាកោះ

A. មន្ត្រីអន្តោប្រវេសន៍អាចត្រូវបានអនុញ្ញាតឱ្យចូលកន្លែងអសាធារណៈនៃបរិវេណមហាវិទ្យាល័យ នៅពេលមានដីកាតុលាការតែប៉ុណ្ណោះ។

(ឧទាហរណ៍នៃកន្លែងអសាធារណៈ៖ ខាងក្រោយបញ្ជរ ការិយាល័យ ថ្នាក់រៀន កន្លែងពិសោធន៍។ល។)

B. ផ្នែកតូចៗនេះមិនអនុវត្តតាមសកម្មភាពដែលមិនមែនជាការអនុវត្តច្បាប់ រួមទាំងសំណើរបស់មន្ត្រីអន្តោប្រវេសន៍ដែលសុំចូលប្រើ ឬសុំព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការរបស់និស្សិតអន្តរជាតិ បុគ្គលិក ឬកម្មវិធីមហាវិទ្យាល័យ ឬកិច្ចខិតខំផ្ទៀងផ្ទាត់ការងារឡើយ។

(ឧទាហរណ៍ ដីកា/ដីកាកោះជាក់លាក់ ប៉ុន្តែមន្ត្រីអនុវត្តន៍ច្បាប់អន្តោប្រវេសន៍កំពុងដើរចុះឡើងសួររកព័ត៌មាន ដែលមិនមានក្នុងដីកា/ដីកាកោះនោះ)។

# 5. ការឆ្លើយតបទៅមន្ត្រីអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ក្នុងបរិវេណមហាវិទ្យាល័យ

A. បុគ្គលទំនាក់ទំនងតែមួយ

1) មណ្ឌលសិក្សាធិការនៃមហាវិទ្យាល័យត្រូវចាត់តាំងបុគ្គលិកម្នាក់ឱ្យធ្វើជាបុគ្គលទំនាក់ទំនងសម្រាប់និស្សិត មហាវិទ្យាល័យ ឬបុគ្គលិកដែលអាចនឹងត្រូវអនុវត្តតាមបទបញ្ជាអន្តោប្រវេសន៍ ឬឆ្លើយសំណួរនៅបរិវេណមហាវិទ្យាល័យ។ សូមទាក់ទងទៅផ្នែកគ្រប់គ្រងហានិភ័យ djefferson@lbcc.edu

2) មហាវិទ្យាល័យ និងបុគ្គលិកត្រូវបានហាមឃាត់មិនឱ្យពិភាក្សាអំពីព័ត៌មានផ្ទាល់ខ្លួន រួមទាំងព័ត៌មានអំពីស្ថានភាពអន្តោប្រវេសន៍របស់និស្សិត មហាវិទ្យាល័យ ឬបុគ្គលិកជាមួយនរណាម្នាក់ ឬបញ្ចេញព័ត៌មានផ្ទាល់ខ្លួននោះដល់នរណាម្នាក់ឡើយ លុះត្រាតែការបញ្ចេញនោះត្រូវបានអនុញ្ញាតដោយច្បាប់រដ្ឋ និងសហព័ន្ធស្តីពីឯកជនភាពនៃការអប់រំ។

# 5. ការឆ្លើយតបទៅមន្ត្រីអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ក្នុងបរិវេណមហាវិទ្យាល័យ (ត)

B. សេវាផ្លូវច្បាប់

1) មណ្ឌលសិក្សាធិការនៃមហាវិទ្យាល័យត្រូវរក្សា និងផ្តល់បញ្ជីឈ្មោះស្ថាប័នផ្តល់សេវាផ្លូវច្បាប់អន្តោប្រវេសន៍ដល់និស្សិត នៅពេលមានការស្នើសុំ និងដោយឥតគិតថ្លៃ នេះជាតំណ៖ https://www.cccco.edu/Students/Support-Services/Special-population/Undocumented-Students/Legal-Services

B. គោលការណ៍គំរូនៃការិយាល័យអគ្គរដ្ឋអាជ្ញា

1) មណ្ឌលសិក្សាធិការនៃមហាវិទ្យាល័យត្រូវអនុម័ត និងអនុវត្តគោលការណ៍គំរូដែលតាក់តែងដោយការិយាល័យ AG ឬគោលការណ៍ដែលមានតម្លៃស្មើ ដើម្បីដាក់កំហិតលើជំនួយពាក់ព័ន្ធនឹងការអនុវត្តច្បាប់អន្តោប្រវេសន៍ក្នុងកម្រិតពេញលេញបំផុត ស្របតាមច្បាប់រដ្ឋ និងសហព័ន្ធ។

ឧទាហរណ៍៖ ភ្នាក់ងារអនុវត្តន៍ច្បាប់ [Long Beach Police Department (LBPD, មន្ទីរប៉ូលិសនៃទីក្រុងឡុងប៊ិក) មិនត្រូវជួយដល់ការអនុវត្តច្បាប់អន្តោប្រវេសន៍ឡើយ ដូចបានគូសបញ្ជាក់ក្នុងគោលការណ៍គំរូរបស់ការិយាល័យ AG លុះត្រាតែមានករណីពិសេសជាក់លាក់។

# 5. ការឆ្លើយតបទៅមន្ត្រីអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ក្នុងបរិវេណមហាវិទ្យាល័យ (ត)

## A. ធនធានអ៊ីនធឺណិត

1) មណ្ឌលសិក្សាធិការត្រូវតែបង្ហាញឱ្យច្បាស់ក្នុងគេហទំព័រលើអ៊ីនធឺណិតរបស់ខ្លួននូវព័ត៌មានបច្ចុប្បន្ន រួមទាំងគោលការណ៍គំរូរបស់ការិយាល័យអគ្គរដ្ឋអាជ្ញា និងការណែនាំពាក់ព័ន្ធ ដែលទាក់ទងនឹងសិទ្ធិរបស់ខ្លួនក្រោមច្បាប់អន្តោប្រវេសន៍របស់រដ្ឋ និងសហព័ន្ធ។

តំណ៖

https://oag.ca.gov/sites/all/files/agweb/pdfs/immigration/higher-education-guidance.pdf

# 5. ការឆ្លើយតបទៅមន្ត្រីអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ក្នុងបរិវេណមហាវិទ្យាល័យ (ត)

A. កំណត់មិនឱ្យនិស្សិតគ្មានឯកសារទទួលខុសត្រូវ

1) ប្រសិនបើនិស្សិតគ្មានឯកសារត្រូវបានឃុំខ្លួន និរទេស ឬមិនអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃការសិក្សារបស់និស្សិត ដោយសារតែវិធានការអន្តោប្រវេសន៍ មណ្ឌលសិក្សាធិការត្រូវខិតខំប្រើគ្រប់មធ្យោបាយសមស្រប ដើម្បីជួយដល់និស្សិតឱ្យបន្តមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ ប្រាក់ឧបត្ថម្ភអាហារូបករណ៍ ការលើកលែងថ្លៃសិក្សាពីអនិវាសនជន ថវិកាសម្រាប់ការស្រាវជ្រាវឬគម្រោងអប់រំផ្សេងទៀត ប្រាក់ឧបត្ថម្ភឬសេវាកម្មសម្រាប់លំនៅឋាន ឬអត្ថប្រយោជន៍ផ្សេងទៀតដែលគាត់ត្រូវបានផ្តល់ឬទទួល និងអនុញ្ញាតឱ្យនិស្សិតចុះឈ្មោះឡើងវិញ ប្រសិនបើនិងនៅពេលដែលនិស្សិតអាចត្រឡប់ចូលមហាវិទ្យាល័យវិញបាន។

ទាក់ទងទៅ៖ ព្រឹទ្ធបុរសផ្នែកកិច្ចការនិស្សិត dmiller-calvert@lbcc.edu

2) គួរមានបុគ្គលិកសម្រាប់ជួយនិស្សិតគ្មានឯកសារ ព្រមទាំងនិស្សិត មហាវិទ្យាល័យ និងបុគ្គលិកផ្សេងទៀត ដែលការអប់រំឬការងាររបស់ខ្លួនប្រឈមនឹងហានិភ័យ ដោយសារតែវិធានការអន្តោប្រវេសន៍សហព័ន្ធ។

ទំនាក់ទំនងសម្រាប់និស្សិត៖ ព្រឹទ្ធបុរសផ្នែកកិច្ចការនិស្សិត dmiller-calvert@lbcc.edu

ទំនាក់ទំនងសម្រាប់បុគ្គលិក៖ ផ្នែកធនធានមនុស្ស rvonkolen@lbcc.edu

# ធនធាន

- គេហទំព័រកណ្តាលមួយដែលមានធនធានពាក់ព័ន្ធនឹងការអនុវត្តច្បាប់អន្តោប្រវេសន៍៖ នឹងជម្រាបតាមក្រោយ
- តំណទៅកាន់ DREAM Services (រូបថតអេក្រង់នៃទំព័រនៅស្លាយបន្ទាប់)៖ https://www.lbcc.edu/dream-services
- តំណទៅកាន់ UndocU Campus Guide (រូបថតអេក្រង់នៃទំព័រនៅស្លាយបន្ទាប់)៖ https://lbcc.instructure.com/courses/38681
- តំណទៅកាន់ សេវាផ្លូវច្បាប់អន្តោប្រវេសន៍នៃមហាវិទ្យាល័យសហគមន៍ (CCCCO)៖ https://www.cccco.edu/Students/Support-Services/Special-population/Undocumented-Students/Legal-Services
- តំណទៅកាន់ Show your Allyship៖ https://lbcc.instructure.com/courses/38681/pages/show-your-allyship
- CHIRLA – ដៃគូផ្តល់សេវាផ្លូវច្បាប់

# ទំព័ររបស់ Dream Services និង UndocU Campus Guide (រូបថតអេក្រង់)

LONG BEACH CITY COLLEGE



## DREAM Services

Long Beach City College is proud to take a stand and support our undocumented students. DREAM Services is dedicated to serving the AB540 and undocumented student population through advocacy, guidance, and support. The programs and services are designed for students to achieve academic, personal, and professional excellence at Long Beach City College.

At its core DREAM Services support and promote a safe space for undocumented students. Our primary focus is to serve, support, and advocate for the academic, professional and personal development and success of all undocumented students at Long Beach City College.

We also hope to educate our campus community about immigration issues through forums, workshops, and community resources available to undocumented students.

**Prospective Students**
Resources for new students
Read more »

**Current Students**
Resources for enrolled students
Read more »

LAC, Welcome Center, A-100 | TTC, AA Bldg.

**DREAM Services**

(562) 938-4151
Send email

Social media

Hours

| | |
|---|---|
| Mon | 8:00 AM - 5:00 PM |
| **Tue** | **8:00 AM - 5:00 PM** |
| Wed | 8:00 AM - 5:00 PM |
| Thu | 8:00 AM - 5:00 PM |
| Fri | 8:00 AM - 12:00 PM |
| Sat | Closed |
| Sun | Closed |

California Dream Act

New Student Checklist

DREAM Services
Student Referral Form



UndocU Campus Guide

Spring 2025 LBCC is proud to support undocumented students

LBCC values its diverse student population and is committed to providing students with high-quality support services. DREAM Services provides support, guidance, and encouragement to excel. Your success is important to us, and we are glad you are here.

New Student Checklist | Meet with a Counselor | Post Election Support

Spring 2025 Workshops

Academic Support | Wellness | Staff & Faculty

# សូមអរគុណ

# សំណួរ-ចម្លើយ

